# គិតអំពីយេនឌ័រ សមភាពយេនឌ័រ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

## យេនឌ័រ ♀♂

សំដៅទៅលើតួនាទី ឥរិយាបថ និងគុណតម្លៃរបស់បុរស និងស្ត្រីដែលកំណត់ដោយសង្គម។ តួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះកំណត់នូវអាកប្បកិរិយា និងទំនាក់ទំនងរវាងបុរសនិងស្ត្រី។ ផ្នត់គំនិតសង្គម ទៅលើតួនាទី ឥរិយាបថ និងគុណតម្លៃទាំងនេះបានកំណត់ថាស្ត្រីត្រូវមានតួនាទីដាំបាយ ថែទាំកូន រីឯបុរសមានតួនាទីរកប្រាក់ចិញ្ចឹមគ្រួសារ បុរសត្រូវចូលដណ្តឹងស្ត្រី ។ល។ ការរើសអើងយេនឌ័រ ធ្វើឱ្យមានវិសមភាពរវាងបុរស និងស្ត្រី ។

“ គិតអំពីយេនឌ័រ!
យេនឌ័រអាចត្រូវបានគេគិតថាជាប្រព័ន្ធសង្គមមួយដែលបង្ហាញពីរបៀបដែលអំណាច និងធនធានត្រូវបានចែកចាយនៅក្នុងសង្គម។ ប្រព័ន្ធនេះជាធម្មតានាំទៅរកវិសមភាពនៃឱកាសនិងឧបសគ្គដែលស្ត្រី និងបុរសជួបប្រទះ។ បទដ្ឋាន និងតួនាទីយេនឌ័រ គឺជាផ្នែកសំខាន់នៃប្រព័ន្ធនេះ។ ”

តួនាទីយេនឌ័រ គឺជាតួនាទីរបស់បុរស និងស្ត្រីដែលកំណត់ដោយសង្គម ប្រសិនបើបុគ្គលណាមួយមិនបានបំពេញតួនាទីយេនឌ័រ ដូចសង្គមរំពឹងទុក ពួកគេអាចប្រឈមមុខនឹងការដាក់ទណ្ឌកម្មពីសង្គម ឧ. ស្ត្រីនៅផ្ទះមើលថែទាំកូន ចំណែកឯបុរសជាមេគ្រួសារ។

# សមភាពយេនឌ័រ

**ការយល់ដឹងអំពីសមភាពយេនឌ័រ គឺជាមូលដ្ឋានគ្រឹះនៃការយល់ដឹង និងការលើកកម្ពស់សិទ្ធិស្ត្រី**

សមភាពយេនឌ័រ គឺជាតួនាទីឥរិយាបថនិងតម្លៃរបស់បុរសនិងស្ត្រីដែលកំណត់ដោយសង្គមដោយគ្មានការរើសអើង។ គ្មានការរើសអើងដោយកំណត់អត្តសញ្ញាណភេទរបស់បុគ្គលណាម្នាក់ធ្វើជាមូលដ្ឋាននៅក្នុងការបែងចែកធនធាន ឬផលប្រយោជន៍ ឬមួយនៅក្នុងការទទួលបានសេវានានា។

សមភាពយេនឌ័រអាចវាស់វែងបានដោយពិនិត្យមើលអំពីការមានឱកាស (កាលានុវត្តភាព) ឬមួយក៏មានការទទួលផលដូចគ្នាសម្រាប់ស្ត្រីនិងបុរស។

អនុសញ្ញានៃអង្គការសហប្រជាជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ គឺជាសេចក្តីថ្លែងការណ៍មួយស្តីពីគោលការណ៍សមភាពយេនឌ័រ ខាងឱកាស (កាលានុវត្តភាព) ដែលគួរតែមាននៅក្នុងការអនុវត្ត ក្នុងគ្រប់រូបភាពនៃការរស់នៅ និងក្នុងគ្រប់ផ្នែកនៃវិស័យសេដ្ឋកិច្ចសង្គម។

ប្រសិនបើអ្នកបានឃើញ ឬបានជួបប្រទះអំពើហិង្សា ឬការរំលោភបំពានលើស្ត្រី សូមទំនាក់ទំនងមកក្រសួងកិច្ចការនារី

០៩៣ ៧៧៧ ៩០០ / ០៨៥ ៧៧៧ ៩០០

www.youtube.com/c/mowacambodiaofficial

# អំពើហិង្សាទាក់ទងនឹងយេនឌ័រ

អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាអំពើរំលោភបំពានទាំងឡាយទៅលើភេទណាមួយ ដែលគេគិតថាទន់ខ្សោយជាងខ្លួន ហើយដែលនាំឱ្យមាន ឬក៏ទំនងជានាំអោយមានសេចក្តីអន្តរាយលើរូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬខាងផ្នែកជីវភាពដោយផ្អែកលើយេនឌ័រនៃបុគ្គលណាមួយ។ តាមធម្មតាគឺសំដៅលើស្ត្រី និងក្មេងស្រីជាអ្នករងគ្រោះតែក៏អាចជាអំពើហិង្សាលើភេទមួយផ្សេងទៀតដែរ។




គ្រប់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងក្មេងស្រីមិនមែនជាជំនឿនៅក្នុងវប្បធម៌ សាសនា ឬប្រពៃណីណាមួយឡើយ។

**ផលិតដោយ**

ក្រសួងកិច្ចការនារី

គាំទ្រដោយ

UNFPA CAMBODIA

## សេចក្តីផ្តើម

នៅកម្ពុជា ស្ត្រី និងក្មេងស្រីនៅតែបន្តរងគ្រោះដោយអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកជីវភាព ក្នុងគ្រប់ស្រទាប់វណ្ណៈ នៅក្នុងជីវិតសាធារណៈ និងឯកជន របស់ពួកគេ។ អំពើហិង្សា លើស្ត្រី និងក្មេងស្រីនៅកម្ពុជាកើតចេញពីកត្តាជាច្រើន ដែលទាក់ទងនឹងឥរិយាបថ និងបទដ្ឋានសង្គមដែលផ្តល់សិទ្ធិ និងអំណាចដល់បុរស និងក្មេងប្រុស ជាងស្ត្រីនិងក្មេងស្រី។ ទម្រង់ផ្សេងៗគ្នានៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី បានកើតឡើងដោយបន្សំនៃកត្តាបុគ្គល ទំនាក់ទំនងសហគមន៍ ស្ថាប័ន និងសង្គម ដែលរើសអើងទៅលើស្ត្រីនិងក្មេងស្រី។ ដូច្នេះ អំពើហិង្សាគួរទទួលបានការឆ្លើយតប ក្នុងការអន្តរាគមន៍ផ្សេងៗលើគ្រប់វិស័យ។

លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ដោយរាប់បញ្ចូលបណ្តាញសង្គមក្នុងការចែករំលែក ការទប់ស្កាត់ និងការឆ្លើយតបចំពោះអំពើហិង្សាលើស្ត្រី និងក្មេងស្រី " បញ្ឈប់ការស្តីបន្ទោសជនរងគ្រោះ " ។




## ប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ

### អំពើហិង្សាលើផ្លូវកាយ

ឧទាហរណ៍៖
រុញ ច្រាន វាយដំ ទាត់ធាក់ ទះកំផ្លៀង វាយនឹងវត្ថុ គប់នឹងវត្ថុ អំពើផ្សេងទៀតដែលបង្កគ្រោះថ្នាក់...។ល។

### អំពើហិង្សាផ្លូវចិត្ត

ឧទាហរណ៍ពីអាកប្បកិរិយាមួយចំនួនដូចជា ៖
ស្រែក ជេរប្រមាថ ធ្វើឱ្យអាម៉ាស់ រិះគន់ គំរាមកំហែង ការប្រើពាក្យអសុរៈ ...។ល។

### អំពើហិង្សាផ្លូវភេទ

ឧទាហរណ៍៖
ការបង្ខំឱ្យរួមភេទ ការចាប់រំលោភ បទប្រទូស្តកេរ្តិ៍ខ្មាស ការបង្ខំឱ្យរៀបការ ឬរុកកួនផ្លូវភេទ...។ល។

### អំពើហិង្សាផ្នែកជីវភាពសេដ្ឋកិច្ច

ឧទាហរណ៍៖ ការបដិសេធមិនឱ្យដៃគូគ្រប់គ្រងធនធានសំខាន់ៗដូចជា ៖

- ការមិនផ្តល់ថវិកា បំផ្លិចបំផ្លាញទ្រព្យ
- ការមិនជួយផ្នែកហិរញ្ញវត្ថុ
- ការបិទសិទ្ធិសេរីភាពក្នុងការរកប្រាក់ចំណូល





## ផលវិបាកនៃអំពើហិង្សា

- សុខភាព

អំពើហិង្សាលើស្ត្រីត្រូវបានផ្សារភ្ជាប់ជាមួយនឹងផលវិបាកធ្ងន់ធ្ងរដល់សុខភាពស្ត្រី និងកុមារ រួមទាំងរបួសផ្លូវកាយ បញ្ហាសុខភាពបន្តពូជ បញ្ហាសុខភាពផ្លូវចិត្ត ការរំលោភបំពាន ការប្រើប្រាស់សារធាតុញៀន សុរា និងជំងឺឆ្លងតាមផ្លូវភេទ។

- ផលប៉ះពាល់លើកុមារ

អំពើហិង្សាលើស្ត្រីក៏មានផលប៉ះពាល់ពេញមួយជីវិតទៅលើសុខភាព និងសុខុមាលភាពរបស់កុមារ និងក្រុមគ្រួសាររបស់ពួកគេ។ ផលប៉ះពាល់មួយចំនួននៃការរងអំពើហិង្សាក្នុងវ័យកុមារភាព ឬការឃើញម្តាយរបស់ពួកគេ ឬមនុស្សជាទីស្រឡាញ់ផ្សេងទៀតកំពុងជួបប្រទះអំពើហិង្សា និងក្លាយជាស្រមោលអន្ទកាល។

- ផ្នែកសង្គម និងសេដ្ឋកិច្ច

ផលប៉ះពាល់សង្គម និងសេដ្ឋកិច្ចនៃអំពើហិង្សាលើស្ត្រីមានចំនួនច្រើន ដោយកាត់បន្ថយផលិតភាព និងការបង្វិលចរន្តថវិកា និងធនធានក្នុងវិស័យជាច្រើន។ អំពើហិង្សាលើស្ត្រីរួមទាំងការចំណាយផ្ទាល់ និងប្រយោលយ៉ាងច្រើនសម្រាប់ជួយដល់ជនរងគ្រោះ/អ្នករស់រានមានជីវិត និយោជក និងវិស័យសាធារណៈ ទាក់ទងនឹងសុខភាព ប៉ូលីស ការចំណាយផ្នែកច្បាប់ និងវិស័យពាក់ព័ន្ធ។ល។